

# ហេតុអ្វីបានជាពិស របស់ពស់ ថ្លាន់ត្រូវ បានបាត់បង់?

Let's Read
The Asia Foundation



មាននារីវ័យក្មេងម្នាក់ដ៏ស្រស់ស្អាតនិង
បុរសវ័យក្មេងម្នាក់ដ៏សង្ហារស់នៅក្នុង
ភូមិមួយឯជនបទក្នុងប្រទេសកម្ពុជា។
ពួកគេបានស្រឡាញ់គ្នាហើយរៀបការ។
ពួកគេរស់នៅដោយសុភមង្គល
ព្រមទាំងថែរក្សាគ្នាទៅវិញទៅមក។
មេឃភ្លឺស្រលះបន្ទាប់ពីភ្លៀងធ្លាក់
មួយរយៈធំ។ បន្ទាប់ពីភ្លៀងប្ដីប្រពន្ធ
នេះបានដើរលើផ្លូវភក់ និងដើរទៅផ្ទះ
ឪពុកម្ដាយរបស់ពួកគេ។ នៅលើផ្លូវ
ភក់បានបន្សល់ទុកនៅស្នាមបាតជើង
របស់នាក់ទាំងពីរដោយមើលឃើញ
យ៉ាងច្បាស់។ ពេលនោះហើយ។
គ្រាន់តែក្រលាស់អណ្ដាតវាទៅលើ



ដីដែលមានស្នាមជើងមនុស្សណា
អ្នកនោះនឹងស្លាប់ដោយសារពិសយ៉ាង
សាហាវ ខណៈនោះពស់ថ្លាន់ក៏បាន
បង្ហាញខ្លួន។ បន្ទាប់មកកូនក្រមុំដ៏
ស្រស់ស្អាតនោះក៏បានស្លាប់ដោយសារ
វាបានក្រលាស់អណ្ដាតពិសរបស់វា
ទៅលើស្នាមជើងដែលកូនក្រមុំបាន
ដើរឆ្លងកាត់, រំពេចនោះកូនក្រមុំក៏បាន
ស្លាប់បាត់ទៅ។



កូនកំលោះដែលបានបាត់បង់កូនក្រមុំ
របស់ខ្លួនក្រោយរៀបកាមិនយូរប៉ុន្មាន
នោះ មានការឈឺចាប់យ៉ាងខ្លាំង។
កូនកំលោះបានយំពីរបីថ្ងៃ ហើយ
បានរៀបចំពិធីបុណ្យសពដើម្បីធ្វើ
ឱ្យ វិញ្ញាណក្ខន្ធកូនក្រមុំបានទៅកាន់
សុគតិភព។ អ្នកភូមិបានប្រមូលផ្តុំគ្នា
នៅពិធីបុណ្យសព។



សត្វពស់ដែលបានឃើញរឿងនេះ
បានសាកសួរទៅសត្វដទៃទៀត។
"ហេតុអ្វីបានជាមនុស្សទាំងនេះ ប្រមូល
ផ្តុំគ្នាសប្បាយចិត្តដូច្នេះ?" ។ សម្លឹង
មើលទៅមនុស្សប្រមូលផ្តុំគ្នាដើម្បី
កាន់ទុក្ខចំពោះការស្លាប់របស់កូនក្រមុំ
និងការថែរក្សាពិធីបុណ្យសពនោះ
ពស់បានយល់ច្រលំថាជាការធ្វើពិធី
ជប់លៀងនៅក្នុងភូមិនេះទៅវិញ។
"ពិធីជប់លៀង? ចង់មានន័យថាម៉េច?
" ទន្សាយនិងកូនកណ្តុរដែលនៅក្បែរ
ភ្ញាក់ផ្អើលយ៉ាងខ្លាំងហើយឆ្លើយថា "អូ,
កូនក្រមុំបានស្លាប់មែនប៉ុន្តែ ខ្ញុំ គិតថា
ប្រជាជនមិនភ័យខ្លាចទេព្រោះ ពិស



របស់ឯងមិនកាចសាហាវដូចអ្វីដែល
បានគិតទេមើលទៅ” ។ ’ប្រសិនបើជា
តិពិសរបស់ឯងកាចសាហាវមែន,
មនុស្សគ្រប់គ្នាភ័យខ្លាចឯងហើយ
ច្បាស់ជាគ្រប់គ្នាភ័យញ័រសង្ងំនៅក្នុង
ផ្ទះមិនខាន។ ប្រមូលផ្តុំគ្នានិយាយពី
សារធាតុពិស ឯងខ្សោយមិនមានអ្វី
អស្ចារ្យទេ’



ពស់ថ្លាន់ដែលតែងតែចង់ក្លាយជាស្ដេច
នៃសត្វនោះ ក៏ធ្លាប់ប្រាថ្នាថា មនុស្ស
និងសត្វមានការភ័យខ្លាចចំពោះខ្លួន
ឯង, ហើយភ័យញ័រ ហើយទទួលការ
គោរពដែលគេតែងគិតខុសកន្លងមក
ពស់ ថ្លាន់បានគិតរួចហើយ។ បើស្ដោះ
ពស់ពិសដែលមាននៅក្នុងរាងកាយ
របស់យើង តើមនុស្សនឹងភ័យខ្លាច
ញ័រហើយឱ្យកិត្តិយសយើងទេ? ពស់
ថ្លាន់បានដកដង្ហើមវែងប្រឹងខ្ជាក់ពិស
ចេញអស់ពីលទ្ធភាពតាមដែលវាអាច
ធ្វើបាន។ ‘អាអាអាអាអាអា’ ពិសបាន
បាញ់ចេញមកពីមាត់ពស់ ថ្លាន់។



’ពស់ ថ្លាន់កំពុងតែខ្ជាក់ពិសរបស់
វា!’ សត្វជាច្រើនមានការភ្ញាក់ផ្អើល
យ៉ាងខ្លាំងដែលបានឃើញនូវសភាព
បែបនេះ។ ឃ្មុំ ដែលមិនមាន ពិស,
ក្អែប, សត្វពស់និងត្រីថន ពួកវាបាន
ចូលទៅក្បែរពស់ ថ្លាន់។ សត្វទាំងនោះ
បានបឺតយកជាតិពិសរបស់ពស់ ថ្លាន់
សត្វឃ្មុំដែលមានតែទឹកមាត់ក៏ចាប់ផ្តើម
មានទ្រនិចមួយផងដែរ, ក្អែប ,សត្វ
ធម្មតា និងត្រីថនដែលគ្មានស្រកា
ពួកវាសុទ្ធតែទទួលបានពិសទាំងអស់។
តើពស់ ថ្លាន់ដែលបានបាត់បង់ពិស
នោះក្លាយទៅជាបែបណា? ត្រូវបាន
គេនិយាយថាចាប់តាំងពីជាតិពិសបាន



បាត់បង់វាក៏បានចូលទៅរស់នៅដោយ
ស្ងៀមស្ងាត់នៅក្នុងព្រៃ។




| 호렝 그림 | 정은주 정리

저는 캄보디아에서 태어난 렉 가나라고 합니다. 한국에 산 지는 11년 되었습니다. 지금은 다시 캄보디아에서 살고 있습니다. 저는 도서관에서 책 읽는 것을 아주 좋아합니다. 그래서 캄보디아의 재미있는 이야기들이 한국에 많이 소개되었으면 좋겠다는 바람을 늘 품어 왔습니다. 이번 제 이야기가 수록되어 많은 국내 이주 여성에게는 희망을, 이야기를 읽는 독자




들에게는 캄보디아의 이야기를 전하는 좋은 기회가 되길 바랍니다.



រហូតមកទល់ពេលនេះអ្នកវិទ្យាសា
ស្ត្របានរុករកចំណេះដឹង,ប្រាជ្ញានិង
បច្ចេកវិទ្យាទំនើបតែមិនអាចរកឃើញ
ភពផ្សេងដែលមនុស្សរស់នៅបាន
ដូច ភពផែនដី ឡើយ។តែមនុស្ស
ទាំងនោះមិនបានឈប់រកភពផ្សេង
ដែលមានជីវិតរស់នៅដូចទៅនិង
ភពផែនដីនុះឡើយ។ គ្មាននណា,និង
គ្មានក្បួនណាដែលអាចរាប់ផ្កាយ
ជាច្រើននៃភពនិមួយៗឡើយ។តែភព
ដែលមនុស្សរស់នៅបានគឺភពផែនដី
តែមួយគត់, អស្ចារ្យបំផុត

ពិតណាស់អារម្មណ៍រំជួលចិត្តនូវ
ពេលដែលបានដឹងនិង។ពិសេស



នៅពេលបានធ្វើការជាមួយនារីប្រទេស
ផ្សេងៗនៅជុំវិញពិភពលោកដែល
មកប្រទេសកូរ៉េតែទទួលអារម្មណ៍
រំជួលចិត្តបំផុត។ភពផែនដីតែមួយ
ទោះយើងជាជនជាតិណាក្តីតែ
ជា គ្រួសារផែនដី ។ គ្រួសារត្រូវ
ទុកចិត្តគ្នា,ពឹងផ្អែកលើគ្នា,និងជួយគ្នា
ទៅវិញទៅមក។ គ្រួសារគឺអោបមុនគេ,
សើចដាក់មុនគេ,និងលះបង់អោយ
មុនគេ។ គ្រួសារគឺរួមទុកជាមួយ
គ្នា,ជំនះការលំបាកជាមួយគ្នា,ត្រូវ
ដើរទៅជាមួយគ្នា។

ខ្ញុំកោតសរសើរដល់អស់អ្នកដែល
បានសរសេរស្នាដៃដ៏អស្ចារ្យតាមរយៈ



ការងារសៀវភៅកុមារ"រួមទាំងគ្នា រួម
ទាំងអស់គ្នា"។ដោយសារតែអ្នកចូលរួម
ទាំងអស់នោះសុទ្ធតែត្រូវចិញ្ចឹម បីបាច់
កូន,ត្រូវធ្វើកិច្ចការផ្ទះ,មើលថែបម្រើ
រមនុស្សចាស់ក្នុងផ្ទះ,និងធ្វើការងារ
ជាដើមទោះបីជាមានការនឿយហត់
យ៉ាងណាក្តីក៏បានបញ្ចប់កាងារបាន
ជោគជយ័។ពិតជាមិនងាយស្រួល
ឡើយសំរាប់ការសរសេរជាភាសាកូរ៉
សំរាប់អ្នកមិនទាន់ច្បាស់ទៅនិងភាសារ
នៅឡើយ។ យ៉ាងណាក្តីការសរសេរ
បង្កប់ឥទ្ធិពលដែលមិនអាចប្រៀបទៅ
និងការនិយាយរាប់រយដង។ ឥទ្ធិពល
បង្ហាញអោយឃើញច្បាស់នៅចិត្តគំនិត



ឥទ្ធិពលនៃសមាសសភាពក្នុងការ
ប្រាស្រ័យទាក់ទងជាមួយអ្នកដ៏ទៃ
ឥទ្ធិពលក្នុងការអប់រំកូនអោយបាន
ល្អ មានឥទ្ធិពលទាំងអស់នេះ ខ្ញុំសូម
ជំរុញឱ្យគម្រោងនេះកើតមានឡើង
រឹតតែច្រើន,ដែលផ្តល់មោទនភាពនិង
ក្តីសង្ឃឹមដល់ស្ត្រីចំណាកស្រុកជាច្រើន
និងគ្រួសាររបស់ពួកគេ។ អ្នកនិពន្ធ,ណូ
ក៉ាំងស៊ីល

In collaboration with and
generously supported by
Seoul
Metropolitan Government,
The Asia Foundation, and
MoneyGram Foundation

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
구렁이의 독은 왜 없어졌을까?, Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2019. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/

Contributing translators: Nasema Zeerak